ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម
ការិយាល័យទទួលពាក្យបណ្តឹង និងស៊ើបអង្កេត

# របាយការណ៍ស្តីពីការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គបឃ.ស
## (គិតត្រឹមថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦)

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| **ខេត្តបាត់ដំបង (លេខកូដ ០២)** | | | | | | | | |
| ១ | | ១០/១០/១៦ | ឈ្មោះ ឡី ទូច ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | មនុស្សមួយក្រុមដែលគ្មានទីលំនៅក្នុងឃុំអន្លង់វង | កម្មវត្ថុ ៖ មនុស្សមួយក្រុម គ្មានទីលំនៅក្នុងឃុំអន្លង់វន បានក្លែងសៀវភៅស្នាក់នៅ ដើម្បីទៅចុះឈ្មោះបោះឆ្នោត។ មូលហេតុ ៖ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ មានមនុស្សមួយក្រុមដែលគ្មានទីលំនៅក្នុងឃុំអន្លង់វន បានក្លែងបន្លំសៀវភៅស្នាក់នៅ ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងឃុំ អន្លង់វន។ | ឃុំអន្លង់វន ស្រុកថ្មគោល ខេត្តបាត់ដំបង | លិខិតជូនដំណឹង | |
| ២ | | ១០/១០/១៦ | ឈ្មោះ ព្រៀច ទូច ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | មនុស្សមួយក្រុមដែលគ្មានទីលំនៅក្នុងឃុំអន្លង់វង | កម្មវត្ថុ ៖ មនុស្សមួយក្រុម គ្មានទីលំនៅក្នុងឃុំអន្លង់វន បានក្លែងសៀវភៅស្នាក់នៅ ដើម្បីទៅចុះឈ្មោះបោះឆ្នោត។ មូលហេតុ ៖ កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ មានមនុស្សមួយក្រុមដែលគ្មានទីលំនៅក្នុងឃុំអន្លង់វន បានក្លែងបន្លំសៀវភៅស្នាក់នៅ ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងឃុំ អន្លង់វន។ | ឃុំអន្លង់វន ស្រុកថ្មគោល ខេត្តបាត់ដំបង | លិខិតជូនដំណឹង | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ៣ | | ១០/១០/១៦ | ឈ្មោះ ថាំ សុខ ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | មនុស្សមួយក្រុមដែលគ្មានទីលំនៅក្នុងឃុំអន្លង់វុង | <u>កម្មវត្ថុ</u> ៖<br>មនុស្សមួយក្រុម គ្មានទីលំនៅក្នុងឃុំអន្លង់វុន បានក្លែងសៀវភៅស្នាក់នៅ ដើម្បីទៅចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ មានមនុស្សមួយក្រុមដែលគ្មានទីលំនៅក្នុងឃុំអន្លង់វុន បានក្លែងបន្លំសៀវភៅស្នាក់នៅ ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងឃុំ អន្លង់វុន។ | ឃុំអន្លង់វុន ស្រុកថ្មគោល ខេត្តបាត់ដំបង | លិខិតជូនដំណឹង | |
| **ខេត្តកំពត (លេខកូដ ០៧)** | | | | | | | | |
| ១ | | ០២/០៩/១៦ | លោក សិន សាឯម ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ដេញ ហៀន និង សំ អាន់ | <u>កម្មវត្ថុ</u> ៖<br>ប្តឹងជំទាស់ឈ្មោះ ដេញ ហៀន និងឈ្មោះ សំ អាន់ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>សង្ស័យជនទាំងពីរនេះមិនមែនជាខ្មែរ បានទៅចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦។ | ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត | ចារបដិសេធ (ប្តឹងជំទាស់ក្នុងពេលចុះឈ្មោះ) | |
| ២ | | ០២/០៩/១៦ | លោក ណែម ប្រុស ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | | <u>កម្មវត្ថុ</u> ៖<br>ប្តឹងជំទាស់ប្រជាពលរដ្ឋចំនួន ០៦ នាក់ ។<br><u>មូលហេតុ</u> ៖<br>សង្ស័យជនទាំងប្រាំមួយនាក់នេះ មិនមែនជាខ្មែរ បានទៅចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០១៦ ។ | ឃុំព្រែកក្រើស ស្រុកកំពង់ត្រាច ខេត្តកំពត | ដើមបណ្តឹងដកពាក្យបណ្តឹង | |
| ៣ | | ០៥/០៩/១៦ | លោក ម៉ាត់ យូសុះ ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | ឈ្មោះ សំ ចរិយា និង កែវ ហ៊ាង មន្ត្រីគណបក្ស | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ សំ ចរិយា និង កែវ ហ៊ាង ពីបទអុកឡុករំខានការចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖ | ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត | ផ្សះផ្សាសះជា | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្ដឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្ដឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | សង្គ្រោះជាតិ | នៅវេលាម៉ោង ១០:១០ នាទីព្រឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ សំ ចរិយា និង កែវ ហ៊ាង ជាមន្ត្រីគណបក្សសង្គ្រោះជាតិ ដែលគ្មានតួនាទីនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បានចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយមិនមានការអនុញ្ញាត និងបានធ្វើសកម្មភាពថតរូបក្នុងការិយាល័យផងដែរ។ | | | |
| **ខេត្តកណ្ដាល** (**លេខកូដ ០៨**) | | | | | | | | |
| ១ | | ២៨/០៩/១៦ | ឈ្មោះ វ៉ែន វិន ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ សុត សុង ប្រធាន ក.ច.ប សង្កាត់ព្រែកហូរ | <u>កម្មវត្ថុ</u> ៖<br>ប្ដឹងឈ្មោះ សុត សុង ប្រធាន ក.ច.ប សង្កាត់ព្រែកហូរ ពីបទមិនចុះឈ្មោះជូនប្រជាពលរដ្ឋ។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ការិយាល័យចុះឈ្មោះបោះឆ្នោត នៃសង្កាត់ព្រែកហូរមិនអាចដំណើរការចុះឈ្មោះបោះឆ្នោតបាន ដោយមូលហេតុថាការីកុំព្យូទ័រ ធ្វើឲ្យកុំព្យូទ័រសើមទឹកមិនអាចដំណើរការបានពេលដែលយកកុំព្យូទ័រទៅផ្ទះ។ | សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល | លិខិតជូនដំណឹង | |
| ២ | | ១៤/១០/១៦ | ឈ្មោះ ជួង ឈុននី ជាជំទប់ទី១ គណបក្សសម រង្ស៊ី | ឈ្មោះ អាន ស្រៀ ជាប្រធាន ក.ច.ប ឃុំព្រះប្រសប់ | <u>កម្មវត្ថុ</u> ៖<br>ប្ដឹងឈ្មោះ អាន ស្រៀ ជាប្រធាន ក.ច.ប ពីបទមិនគោរពច្បាប់ មានគំនិតមិនល្អ លំអៀង មិនមែនជាបុគ្គលអព្យាក្រឹត។<br><u>មូលហេតុ</u> ៖<br>លោក អាន ស្រៀ មិនមានជំហរអព្យាក្រឹត រើសអើងនិន្នាការនយោបាយ មិនគោរពច្បាប់ដូចជាការចែកប័ណ្ណលេខរៀងជូនពលរដ្ឋ ការធ្វើឯកសារបញ្ជាក់ជូនប្រជាពលរដ្ឋ ការប្រើសម្ដីឌឺដង និងបញ្ហាប្រើពាក្យសម្ដីផ្ដាំផ្ញើងជាសម្ពាតដល់ភ្នាក់ងារគណបក្សសង្គ្រោះជាតិ។ (សុំថតចម្លង ទ.១០២៩ មិនព្រមឱ្យថត និងស្ដីឱ្យនាងខ្ញុំទាំងបំពាន មិនមានហេតុផល) | ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល | ផ្សះផ្សាសះជា | |

| លរ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ៣ | | ១៦/១០/១៦ | ឈ្មោះ រស់ ធារី ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | គណបក្សសង្គ្រោះជាតិ | <u>កម្មវត្ថុ</u> ៖<br>ការចែកប័ណ្ណខុសគោលការណ៍ របស់គណបក្សសង្គ្រោះជាតិ។<br><u>មូលហេតុ</u> ៖<br>ការផ្សព្វផ្សាយខុសគោលការណ៍ ប្រព្រឹត្តខុសបទបញ្ជា និងនីតិវិធី គ្មានការអនុញ្ញាតឱ្យចែកលិខិតផ្សេងៗ បែរជាទៅចែកចាយលិខិត។ | ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល | ផ្សះផ្សាសះជា | |
| **រាជធានីភ្នំពេញ** (**លេខកូដ ១២**) | | | | | | | | |
| ១ | | ០៨/០៩/១៦ | លោក នឿន យ៉ាំងកូ ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | នគរបាល បង្ក្រាបបាតុកម្ម | <u>កម្មវត្ថុ</u> ៖<br>ប្តឹងនគរបាលបង្ក្រាបបាតុកម្ម ពីបទរាំងប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី០៥ ខែកញ្ញា វេលាម៉ោង ៦:២៥ នាទីព្រឹក ដល់ម៉ោង ១១:៣០ នគរបាលបានបិទកំណាត់ផ្លូវជាតិលេខ២ ត្រង់ចំណុចមុខវត្តចាក់អង្រែក្រោម កែងផ្លូវ ៦០ ដែលធ្វើឲ្យប្រជាពលរដ្ឋមិនអាចធ្វើដំណើរទៅចុះឈ្មោះបោះឆ្នោតបាន។ | សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ចារបដិសេធ (កបឃ.ស គ្មានសមត្ថកិច្ច) | ប្តឹងបន្តមក គ.ជ.ប |
| ២ | | ០៨/០៩/១៦ | លោក ព្រុំ ហេង ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | នគរបាល បង្ក្រាបបាតុកម្ម | <u>កម្មវត្ថុ</u> ៖<br>ប្តឹងនគរបាលបង្ក្រាបបាតុកម្ម ពីបទរាំងប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត ។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី០៥ ខែកញ្ញា វេលាម៉ោង ៦:២៥ នាទីព្រឹក ដល់ម៉ោង ១១:៣០ នគរបាលបានបិទកំណាត់ផ្លូវជាតិលេខ២ ត្រង់ចំណុចមុខអតីតរោងចក្រ MPP ដែលធ្វើឲ្យប្រជាពលរដ្ឋមិនអាចធ្វើដំណើរទៅចុះឈ្មោះបោះឆ្នោតបាន។ | សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ចារបដិសេធ (កបឃ.ស គ្មានសមត្ថកិច្ច) | ប្តឹងបន្តមក គ.ជ.ប |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្ដឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្ដឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ៣ | | ១៤/០៩/១៦ | ឈ្មោះ ភោគ លីណា តំណាងប្រជាពលរដ្ឋ | ប្រធាន ក.ច.ប សង្កាត់អូរឫស្សី ២ ខណ្ឌ៧មករា រាជធានីភ្នំពេញ | **កម្មវត្ថុ ៖** ប្ដឹងប្រធាន ក.ច.ប សង្កាត់អូរឫស្សី២ ពីបទរារាំងប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត។ **មូលហេតុ ៖** កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១៥:០០ ប្រជាពលរដ្ឋឈ្មោះ អ៊ា សុខហួង បានទៅចុះឈ្មោះបោះឆ្នោតនៅសង្កាត់អូរឫស្សី២ ប៉ុន្តែត្រូវបានប្រធាន ក.ច.ប បដិសេធមិនព្រមចុះឈ្មោះបោះឆ្នោតឲ្យ ដោយអះអាងថាគាត់គ្មានទីលំនៅក្នុងសង្កាត់ (លក់ផ្ទះ) និងមិនព្រមចេញ ទ.១០០៩ ឲ្យទៀត។ | សង្កាត់អូរឫស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ៤ | | ១៦/០៩/១៦ | ឈ្មោះ ទេព ច័ន្ទសុខខែយ៉ា ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ជេត ប៊ុនធឿន ប្រធាន ក.ច.ប សង្កាត់ អូរឫស្សី៤ | **កម្មវត្ថុ ៖** ប្ដឹងឈ្មោះ ជេត ប៊ុនធឿន ប្រធាន ក.ច.ប សង្កាត់អូរឫស្សី៤ ពីបទរារាំងការចុះឈ្មោះបោះឆ្នោត។ **មូលហេតុ ៖** កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១១:០៥ នាទីព្រឹក ប្រជាពលរដ្ឋឈ្មោះ នុច គឹមស៊ាង បានទៅសុំលិខិតបញ្ជាក់ទីលំនៅ ដោយមានភ្នាក់ងារគណបក្សសង្គ្រោះជាតិដែលសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃសង្កាត់អូរឫស្សី៤ ជាសាក្សី ប៉ុន្តែត្រូវប្រធាន ក.ច.ប បដិសេធ មិនព្រមចេញលិខិតបញ្ជាក់ទីលំនៅឲ្យ។ | សង្កាត់អូរឫស្សី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ | ផ្សះផ្សាសះជា | |
| ៥ | | ២០/០៩/១៦ | ឈ្មោះ ប្រាក់ សីហា ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ឌុច ឌឿន ប្រធាន ក.ច.ប សង្កាត់កំបូល | **កម្មវត្ថុ ៖** ប្ដឹងឈ្មោះ ឌុច ឌឿន ប្រធាន ក.ច.ប សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ **មូលហេតុ ៖** កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ៧:៣០ នាទីព្រឹក ឈ្មោះ ឌុច ឌឿន មិនព្រមឲ្យឈ្មោះ | សង្កាត់កំបូល ពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ផ្សះផ្សាសះជា | |

| លរ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | ប្រាក់ សីហា ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ ពិនិត្យមើលទិន្នន័យនៅពេលបើកការិយាល័យចុះឈ្មោះ តាមសេចក្តីណែនាំរបស់ គ.ជ.ប លេខ ៧៩៩/១៦ គ.ជ.ប ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦។ | | | |
| ៦ | | ២១/០៩/១៦ | ឈ្មោះ ខឿន វីរ៉ាត់ ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ប្រាជ្ញ ច័ន្ទសុម៉ាលី មន្ត្រីសាលាសង្កាត់ និងឈ្មោះ ណុប សាគុណ ភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | __កម្មវត្ថុ__ ៖<br>ប្តឹងឈ្មោះ ប្រាជ្ញ ច័ន្ទសុម៉ាលី និងឈ្មោះ ណុប សាគុណ ពីបទបង្កការរំខាន និងរារាំងប្រជាពលរដ្ឋធ្វើលិខិតបញ្ជាក់ទីលំនៅ។<br>__មូលហេតុ__ ៖<br>ប្រជាពលរដ្ឋឈ្មោះ ហ៊ីង សៅលីង ទីសុំលិខិតបញ្ជាក់ទីលំនៅ តែត្រូវឈ្មោះ ប្រាជ្ញ ច័ន្ទសុម៉ាលី និងឈ្មោះ ណុប សាគុណ មិនព្រមធ្វើឲ្យ ដោយតម្រូវឲ្យសាមីខ្លួននាំម្ចាស់ផ្ទះជួល ឬកិច្ចសន្យាជួលផ្ទះមកជាមួយ ទើបព្រមចេញលិខិតបញ្ជាក់ទីលំនៅឲ្យ។ | សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ផ្សះផ្សាសះជា | |
| ៧ | | ២៧/០៩/១៦ | ឈ្មោះ ព្រាប ស៊ា ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ប្រធាន ក.ច.ប សង្កាត់បឹងកេងកង២ | __កម្មវត្ថុ__ ៖<br>ប្តឹងប្រធាន ក.ច.ប សង្កាត់បឹងកេងកង២ ពីបទមិនបំពេញភារកិច្ចក្នុងម៉ោងរដ្ឋបាល។<br>__មូលហេតុ__ ៖<br>កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១៤:០០ ដល់ម៉ោង ១៧:៣០ ប្រធាន ក.ច.ប សង្កាត់បឹងកេងកង២ មិនបានស្ថិតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតនៃង្កាត់បឹងកេងកង២ ទេ។ | សង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ | លិខិតជូនដំណឹង | ប្តឹងបន្តមក គ.ជ.ប |
| ៨ | | ២៨/០៩/១៦ | ឈ្មោះ ហ៊ីង មុនីន្ទ ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ប្រធាន ក.ច.ប សង្កាត់ទួលស្វាយព្រៃ២ | __កម្មវត្ថុ__ ៖<br>ប្តឹងប្រធាន ក.ច.ប សង្កាត់ទួលស្វាយព្រៃ២ ពីបទមិនបំពេញភារកិច្ចរបស់ខ្លួនក្នុងម៉ោងរដ្ឋបាល។<br>__មូលហេតុ__ ៖<br>កាលពីថ្ងៃទី២៥ និងទី២៦ ខែកញ្ញា ឆ្នាំ២០១៦ | សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ | លិខិតជូនដំណឹង | ប្តឹងបន្តមក គ.ជ.ប |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្ដឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្ដឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | មិនបានបំពេញភារកិច្ចរបស់ខ្លួនក្នុងម៉ោងរដ្ឋបាល ដោយគ្មានមូលហេតុ។ | | | |
| ៩ | | ២៨/០៩/១៦ | ឈ្មោះ ទេព ច័ន្ទសុខខៃយ៉ា ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ម៉ៅ គន្ធា ជាការីកុំព្យូទ័រ នៅសង្កាត់អូរឫស្សីទី៤ | <u>កម្មវត្ថុ</u> ៖<br>ប្ដឹងឈ្មោះ ម៉ៅ គន្ធា ជាការីកុំព្យូទ័រ សង្កាត់អូរឫស្សីទី៤ ពីបទ បង្កើតភាពស្មុគស្មាញដល់ប្រជាពលរដ្ឋ។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ ម៉ៅ គន្ធា បានបញ្ចូលលេខផ្ទះរបស់ប្រជាពលរដ្ឋឈ្មោះ ស្រី សុវណ្ណ និងឈ្មោះ ឈាង ជៀបសៃ ច្រឡំគ្នា។ | សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ | ផ្សះផ្សាមិនសះជា | ប្ដឹងបន្តមក គ.ជ.ប |
| ១០ | | ២៩/០៩/១៦ | ឈ្មោះ រៀម សុជាត ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ប្រធាន ក.ច.ប សង្កាត់អូឡាំពិក | <u>កម្មវត្ថុ</u> ៖<br>ប្ដឹងប្រធាន ក.ច.ប សង្កាត់អូឡាំពិក ពីបទមិនបំពេញភារកិច្ចរបស់ខ្លួនក្នុងម៉ោងរដ្ឋបាល។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១៥:០៤នាទីរសៀល គាត់បានចេញទៅខាងក្រៅ លុះដល់ម៉ោង ៥:៣០នាទី ដោយគ្មានមូលហេតុ។ | សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ | លិខិតជូនដំណឹង | |
| ១១ | | ០៦/១០/១៦ | ឈ្មោះ គួច និមល ជាប្រធាន ក.ច.ប | ឈ្មោះ សុខ សុផល ភេទប្រុស ជាប្រជាពលរដ្ឋ | <u>កម្មវត្ថុ</u> ៖<br>ប្ដឹងឈ្មោះ សុខ សុផល ភេទប្រុស ជាប្រជាពលរដ្ឋ ពីបទបង្កការអុកឡុកក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ សុខ សុផល ភេទប្រុស បានមកសុំចុះឈ្មោះបោះឆ្នោតនៅការិយាល័យ សង្កាត់ផ្សារដើមថ្កូវ ប៉ុន្តែអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណខុសពីទីកន្លែងចុះឈ្មោះ ហើយបានណែនាំគាត់ឱ្យរកសាក្សីម្នាក់ ប៉ុន្តែជននោះមិនបានស្ដាប់ | សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ | ផ្សះផ្សាសះជា | |

| លរ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | ក្រុមចុះឈ្មោះបោះឆ្នោតទេ ព្រមទាំងស្រែកឡូឡា និងទះតុខ្លាំង ពេលនោះក្រុមចុះឈ្មោះបានឱ្យកម្លាំងនគរបាលនាំខ្លួនជននោះទៅ នគរបាលប៉ុស្តិ៍ដើម្បីចាត់ការបន្ត។ | | | |
| **ខេត្តសៀមរាប (លេខកូដ ១៧)** | | | | | | | | |
| ១ | | ១០/០៩/១៦ | លោក ជិន សុខង៉េង ជាតំណាងគណបក្សសង្គ្រោះជាតិ | លោក សូរ ប្លាតុង អភិបាលក្រុងសៀមរាប | <u>កម្មវត្ថុ</u> ៖ ប្តឹងឈ្មោះ សូរ ប្លាតុង ពីបទរាំងប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត។ <u>មូលហេតុ</u> ៖ កាលពីថ្ងៃទី១០ ខែកញ្ញា វេលាម៉ោង ១០:០០ នាទីព្រឹក នៅមុខផ្សារសាមគ្គី ស.ក ស្លក្រាម ឈ្មោះ សូរ ប្លាតុង បានដឹកនាំកម្លាំងសមត្ថកិច្ច មករាំងក្រុមយុវជនមិនឲ្យផ្សព្វផ្សាយព័ត៌មាន និងអញ្ជើញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត។ | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | លិខិតជូនដំណឹង | ប្តឹងបន្តមក គ.ជ.ប |
| ២ | | ១១/០៩/១៦ | រដ្ឋបាលក្រុងសៀមរាប | គណបក្សសង្គ្រោះជាតិ | <u>កម្មវត្ថុ</u> ៖ ប្តឹង គណបក្សសង្គ្រោះជាតិ ពីបទធ្វើឲ្យខូចសណ្តាប់ធ្នាប់ ។ <u>មូលហេតុ</u> ៖ កាលពីថ្ងៃទី១០ ខែកញ្ញា វេលាម៉ោង ១០:០០ នាទីព្រឹក នៅមុខផ្សារសាមគ្គី ស.ក ស្លក្រាម គណបក្សសង្គ្រោះជាតិបានធ្វើការប្រមូលផ្តុំ និងហែក្បួនតាមដងផ្លូវសាធារណៈដោយខុសច្បាប់ ដែលធ្វើឲ្យកកស្ទះចរាចរ។ | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | លិខិតជូនដំណឹង | ប្តឹងបន្តមក គ.ជ.ប |
| ៣ | | ១៥/០៩/១៦ | ឈ្មោះ ឃិន វណ្ណី តំណាងគណបក្សសង្គ្រោះជាតិ | ក.ច.ប សង្កាត់ស្លក្រាម ក្រុងសៀមរាប | <u>កម្មវត្ថុ</u> ៖ ប្តឹងសមាសភាព ក.ច.ប សង្កាត់ស្លក្រាម ពីបទយកកុំព្យូទ័រចេញពីការិយាល័យ ក្នុងចេតនាឃុបឃិតគ្នាកែទិន្នន័យអ្នកបោះឆ្នោត។ <u>មូលហេតុ</u> ៖ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | ផ្សះផ្សាមិនសះជា | ប្តឹងបន្តមក គ.ជ.ប |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | ១៨:០០ នាទី សមាសភាព ក.ច.ប បានយកកុំព្យូទ័រចេញពីការិយាល័យចុះឈ្មោះបោះឆ្នោត សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ | | | |
| ៤ | | ១៩/០៩/១៦ | ឈ្មោះ ជិន សុខង៉េង តំណាងគណបក្សសង្គ្រោះជាតិ | ឈ្មោះ ទុយ លីណា និង ឈ្មោះ សេង សុគន្ធា ប្រធាន និងអនុប្រធាន ក.ច.ប សង្កាត់ស្លក្រាម | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ ទុយ លីណា និង ឈ្មោះ សេង សុគន្ធា ប្រធាន និងអនុប្រធាន ក.ច.ប សង្កាត់ស្លក្រាម ពីបទបង្ខំភ្នាក់ងារគណបក្សសង្គ្រោះជាតិ ឲ្យផ្តិតមេដៃទទួលស្គាល់ លើកំណត់ហេតុទទួល Hash Data ពីថ្ងៃទី១ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១១:០០នាទីព្រឹក ឈ្មោះ ទុយ លីណា និងឈ្មោះ សេង សុគន្ធា បានហៅឈ្មោះ ព្រៀង ប៊ុនណារី ភេទស្រី ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ មកផ្តិតមេដៃទទួលស្គាល់ លើកំណត់ហេតុទទួល Hash Data ពីថ្ងៃទី១ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ដោយពុំបានអានឲ្យឈ្មោះ ព្រៀង ប៊ុនណារី ស្តាប់នោះទេ។ | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | ផ្សះផ្សាសះជា | |
| ៥ | | ២១/០៩/១៦ | ឈ្មោះ នូ ណុប ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ សេង ភិរុណ អនុប្រធាន ក.ច.ប ឃុំសំរោង | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ សេង ភិរុណ អនុប្រធាន ក.ច.ប ពីបទប្រើកលល្បិចបញ្ជាឲ្យការីកុំព្យូទ័រព្រីនបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប ។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឈ្មោះ សេង ភិរុណ បានបញ្ជាឲ្យការីកុំព្យូទ័រព្រីនបញ្ជីឈ្មោះអ្នកបោះឆ្នោតឃុំសំរោង ដោយបញ្ជីនោះមានឈ្មោះរូបថត និងលេខកូដការិយាល័យបោះឆ្នោត។ | ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប | ផ្សះផ្សាមិនសះជា | ប្តឹងបន្តមក គ.ជ.ប |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ៦ | | ២១/០៩/១៦ | ឈ្មោះ គីក មៅ ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | ឈ្មោះ ឆេង លី សមាជិកក្រុមប្រឹក្សាសង្កាត់អំពិលនៃគណបក្សសម រង្ស៊ី | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ គីក មៅ សមាជិកក្រុមប្រឹក្សាសង្កាត់ប្រចាំការ ពីបទរារាំង និងរំខានប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១០:៣០ ឈ្មោះ គីក មៅ បានធ្វើសកម្មភាពយកឯកសាររបស់ប្រជាពលរដ្ឋដែលមកចុះឈ្មោះបោះឆ្នោតទៅពិនិត្យ និងថតរូបទុក ដោយគ្មានការអនុញ្ញាតពីសាមីខ្លួន។ | សង្កាត់អំពិល ក្រុងសៀមរាប ខេត្តសៀមរាប | ផ្សះផ្សាសះជា | |
| ៧ | | ២២/០៩/១៦ | ឈ្មោះ ប៉ោង អ៊ីន ជាភ្នាក់ងារគណបក្សប្រជាជនកម្ពុជា | ឈ្មោះ នូ ណុប ភ្នាក់ងារគណបក្សសង្គ្រោះជាតិ | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះនូ ណុប ភ្នាក់ងារគណបក្សសង្គ្រោះជាតិ ពីបទយកអត្តសញ្ញាណប័ណ្ណ និង ទ.១០២២ របស់ប្រជាពលរដ្ឋ។<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១០:២២ នាទីព្រឹក ឈ្មោះ នូ ណុប បានធ្វើសកម្មភាពប្រមូលយកអត្តសញ្ញាណប័ណ្ណ និងទ.១០២២ របស់ប្រជាពលរដ្ឋទៅទុកមួយសន្ទុះក្រោយមកទើបយកមកវិញ។ | ឃុំសំរោង ស្រុកសុទ្រនិគម ខេត្តសៀមរាប | ផ្សះផ្សាសះជា | |
| ៨ | | ២៧/០៩/១៦ | ឈ្មោះ សៀក ចំណាប់ ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ឌី សំណាង ប្រធាន ក.ច.ប | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ ឌី សំណាង ប្រធាន ក.ច.ប ពីបទមិនអនុវត្តតាមសេចក្តីណែនាំ និងនីតិវិធីរបស់ គ.ជ.ប<br><u>មូលហេតុ</u> ៖<br>កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦ លោក ឌី សំណាង ប្រធាន ក.ច.ប មិនបានរៀបចំទីកន្លែង និងដាក់ស្លាកសញ្ញាសម្គាល់តុប្រធានក្រុមប្រឹក្សាសង្កាត់ និងបានជំរុញលើកទឹកចិត្តឱ្យលោក អោម ជន ដែលជាក្រុមប្រឹក្សាសង្កាត់ នាំយកទម្រង់ឯកសារសម្រាប់បញ្ជាក់ទីលំ | សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប | ដើមបណ្តឹងដកពាក្យបណ្តឹង | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | នៅ និងបញ្ជាក់អត្តសញ្ញាណទៅខាងក្រៅការិយាល័យ ដែលធ្វើឱ្យមានភាពមិនប្រក្រតីក្នុងការផ្តល់លិខិតបញ្ជាក់ទីលំនៅ និងលិខិតបញ្ជាក់អត្តសញ្ញាណ។ | | | |
| ៩ | | ០៨/១០/១៦ | ឈ្មោះ សៀក ចំណាប់ តំណាង គណបក្សសង្គ្រោះជាតិ | ឈ្មោះ អៀម អ៊ា អនុប្រធានភូមិកន្ត្រក និងឈ្មោះ ធូន ជា ប្រជាការពារភូមិកន្ត្រក់ | <u>កម្មវត្ថុ</u> ៖<br>ប្តឹងឈ្មោះ អៀម អ៊ា និងឈ្មោះ ធូន ជា ពីបទគំរាមកំហែងប្រជាពលរដ្ឋដែលទៅចុះឈ្មោះបោះឆ្នោត<br><u>មូលហេតុ</u> ៖<br>កាលពីព្រឹកថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ អៀម អ៊ា និងឈ្មោះ ធូន ជា បានធ្វើសកម្មភាពឈរកាក់ និងបានទាមទារ ទ.១០២២ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ប្រជាពលរដ្ឋដែលចុះឈ្មោះបោះឆ្នោតហើយ។ | សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប | ផ្សះផ្សាសះជា | |
| ១០ | | ១០/១០/១៦ | ឈ្មោះ ហួត រ័ត្នមុនី ភ្នាក់ងារ គណបក្សប្រជាជនកម្ពុជា | អនុប្រធាន ក.ច.ប និងការីកុំព្យូទ័រ សង្កាត់ស្លក្រាម | <u>កម្មវត្ថុ</u> ៖<br>ភាពមិនប្រក្រតីរបស់អនុប្រធាន ក.ច.ប និងការីកុំព្យូទ័រដែលមានឈ្មោះ ១. អ្នកស្រី ម៉ាក់ គុលា ២.លោក ទូច ថាន ៣.លោក ម៉ូត និមល និង៤.កញ្ញា ឈន រក្សា បានចាកចេញពីតុ និងកុំព្យូទ័ររបស់ខ្លួនទៅជូនដំណើរមន្ត្រី CNRP ដែលមកពិនិត្យដំណើរការចុះឈ្មោះបោះឆ្នោត។<br><u>មូលហេតុ</u> ៖<br>នៅព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១០:៣០នាទី មានក្រុមប្រតិភូមួយក្រុមមកពីគណបក្សសង្គ្រោះជាតិ ដឹកនាំដោយលោកស្រី កែវ សុវណ្ណរដ្ឋ រួមដំណើរមានជនជាតិបរទេស០១រូប ជាតំណាងរាស្ត្រប្រទេសអាឡឺម៉ង់ និងជនជាតិខ្មែរ៣រូប។ ដោយបានការអនុញ្ញាតពីលោកប្រធាន ក.ច.ប ឈ្មោះ ទី លីណា។ | សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប | ផ្សះផ្សាសះជា | |

| ល.រ | សំណុំរឿងលេខ | កាលបរិច្ឆេទ | ដើមបណ្តឹង | ចុងចម្លើយ | កម្មវត្ថុ និងមូលហេតុនៃបណ្តឹង | កន្លែងកើតហេតុ | ចំណាត់ការ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ខេត្តព្រះសីហនុ (លេខភូដ ១៨) | | | | | | | | |
| ១ | | ០៨/០៩/១៦ | លោក ឡាយ សាបាន ជាភ្នាក់ងារគណបក្សសង្គ្រោះជាតិ | ឈ្មោះ ជេត ប៊ុណ្ណា ជាជំទប់ទី១ ឃុំកំពង់សីលា | កម្មវត្ថុ ៖ ប្តឹងឈ្មោះ ជេត ប៊ុណ្ណា ដែលបានបំពានច្បាប់បោះឆ្នោត។ មូលហេតុ ៖ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ បានចេញលិខិតបញ្ជាក់ទីលំនៅដោយមិនគោរពតាមបទបញ្ញា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ។ | ឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ | ផ្សះផ្សាសះជា | |

**កំណត់សម្គាល់៖**

ក. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គបឃ.ស សរុបមានចំនួន ៣១ បណ្តឹង (គណបក្សប្រជាជនកម្ពុជា ០៥ បណ្តឹង, គណបក្សសង្គ្រោះជាតិ ២២ បណ្តឹង, គណបក្សសម រង្ស៊ី ០១ បណ្តឹង, អាជ្ញាធរ ០១ បណ្តឹង, ប្រជាពលរដ្ឋ ០១ បណ្តឹង, ប្រធាន ក.ច.ប ០១ បណ្តឹង) ៖

**ខេត្តបាត់ដំបង ០៣ បណ្តឹង (គណបក្សសង្គ្រោះជាតិ ០៣ បណ្តឹង)**

- លិខិតជូនដំណឹង ០៣ បណ្តឹង

**ខេត្តកំពត ០៣ បណ្តឹង (គណបក្សប្រជាជនកម្ពុជា ០១ បណ្តឹង, គណបក្សសង្គ្រោះជាតិ ០២ បណ្តឹង)**

- ផ្សះផ្សាសះជា ០១ បណ្តឹង
- ដើមបណ្តឹងដកពាក្យបណ្តឹង ០១ បណ្តឹង
- ចារបដិសេធ ០១ បណ្តឹង

**ខេត្តកណ្តាល ០៣ បណ្តឹង (គណបក្សសង្គ្រោះជាតិ ០១ បណ្តឹង, គណបក្សសម រង្ស៊ី ០១ បណ្តឹង, គណបក្សប្រជាជនកម្ពុជា ០១ បណ្តឹង)**

- លិខិតជូនដំណឹង ០១ បណ្តឹង
- ផ្សះផ្សាសះជា ០២ បណ្តឹង

**រាជធានីភ្នំពេញ ១១ បណ្តឹង (គណបក្សសង្គ្រោះជាតិ ០៩ បណ្តឹង, ប្រជាពលរដ្ឋ ០១ បណ្តឹង, ប្រធាន ក.ច.ប ០១ បណ្តឹង)**

- លិខិតជូនដំណឹង ០៤ បណ្តឹង
- ផ្សះផ្សាសះជា ០៤ បណ្តឹង
- ផ្សះផ្សាមិនសះជា ០១ បណ្តឹង
- ចារបដិសេធ ០២ បណ្តឹង

**ខេត្តសៀមរាប ១០ បណ្តឹង (គណបក្សប្រជាជនកម្ពុជា ០៣ បណ្តឹង, គណបក្សសង្គ្រោះជាតិ ០៦ បណ្តឹង, អាជ្ញាធរ ០១)**

- ដើមបណ្តឹងដកពាក្យបណ្តឹង ០១ បណ្តឹង
- លិខិតជូនដំណឹង ០២ បណ្តឹង
- ផ្សះផ្សាសះជា ០៥ បណ្តឹង
- ផ្សះផ្សាមិនសះជា ០២ បណ្តឹង

**ខេត្តព្រះសីហនុ ០១ បណ្តឹង (គណបក្សសង្គ្រោះជាតិ ០១ បណ្តឹង)**

- ផ្សះផ្សាសះជា ០១ បណ្តឹង

**ខ. ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ នៅ គបឃ.ស មិនទទួលបានពាក្យបណ្តឹងទេ។**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦

**ប្រធានការិយាល័យ**

**ហួត បូរិន**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម

**អនុប្រធាននាយកដ្ឋាន**

**ឌីណា សាគុណា**

បានឃើញ និងឯកភាព

**ប្រធាននាយកដ្ឋាន**

**កែវ ផល្លា**